مدرسة اهل البيت

# សាលា
# អាស់ហុល-បៃត៍

## សៀវភៅ គូរអាន (اَلْقُرْآنُ) ថ្នាក់ទី ២

(អាយុ ៦-៧ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តា ﷺ មានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ច លើមុស្លីមប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ អារម្ភបទនិងសព្ទបច្ចេកទេស ............ ៦
មេរៀនទី ២ ម៉ាខ៉រីជ (ا, ع, ء) ............ ១០
មេរៀនទី ៣ ម៉ាខ៉រីជ (ت, ط, ث) ............ ១៣
មេរៀនទី ៤ ម៉ាខ៉រីជ (س, ص, ز) ............ ១៦
មេរៀនទី ៥ ម៉ាខ៉រីជ (ذ, ظ, ض) ............ ១៩
មេរៀនទី ៦ ម៉ាខ៉រីជ (ه, ح) ............ ២២
មេរៀនទី ៧ ម៉ាខ៉រីជ (ك, ق, خ, غ) ............ ២៥
មេរៀនទី ៨ ម៉ាខ៉រីជ (ហ្វ៊ារុហ្វងទៀត) ............ ២៨
មេរៀនទី ៩ ម៉ាខ៉រីជ - រៀនសាឡើងវិញ ............ ៣១
មេរៀនទី ១០ កាស់រ៉ោះត៍ (الكَسْرَةُ) ............ ៣៣
មេរៀនទី ១១ ដុំម៉ាស់ (الضَمَّةُ) ............ ៣៥
មេរៀនទី ១២ ម៉ាខ៉រីជ - រៀនសាឡើងវិញ ............ ៣៨
មេរៀនទី ១៣ ស៊ូគូន (اَلسُّكُونُ) ............ ៣៩
មេរៀនទី ១៤ តាន់វីន (تَنْوِينٌ) ............ ៤២
មេរៀនទី ១៥ តាស់ឌីដ (تَشْدِيْد) ឬ ស្ហាដ់ដាស់ (شَدَّة) ............ ៤៥
មេរៀនទី ១៦ ស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ............ ៤៨
មេរៀនទី ១៧ ស៊ូរ៉ោះត៍ អាល់-ហ្វាទីហ៊ាស់ - ទន្ទេញចាំរត់មាត់ - តាហ្ស៊ៀរ ............ ៤៩

# اَلْقُرْآنُ



ឈ្មោះខ្ញុំ ៖.........................................................

ឈ្មោះខ្ញុំជាភាសាអារ៉ាប់ ៖

.........................................................................

**មេរៀនទី ១**

# អារម្ភបទនិងសព្ទបច្ចេកទេស

## ព្រះមហាគម្ពីរគួរអានគឺអ្វី ?

ព្រះមហាគម្ពីរគួរអានគឺសៀវភៅ ឬ តម្រា ដែលមានចារនូវព្រះរាជបន្ទូល (គឺសម្តី) របស់អល់ឡោះហ្ ﷻ ។

## អ្នកណាតែងព្រះមហាគម្ពីរគួរអានឡើង ?

មិនមានអ្នកណាតែងព្រះគម្ពីរគួរអានឡើងទេ ។ អល់ឡោះហ្ ﷻ បានបញ្ជូនពាក្យពេជន៍មកឲ្យព្រះសាស្តា ﷺ (ណាប៊ី) តាមរយៈទេវតាឈ្មោះយ៉ិបរ៉អ៊ីល عليه السلام ។

បន្ទាប់មកព្រះសាស្តា ﷺ បានសូត្រព្រះរាជឱង្ការ (អាយ៉ាត់) ប្រាប់មនុស្ស ។ មនុស្សភាគច្រើនចងចាំព្រះរាជឱង្ការរត់មាត់ តែព្រះសាស្តា ﷺ បានចាត់តាំងមនុស្សពីរបីនាក់ដើម្បីសរសេរព្រះឱង្ការទុក ។

## ព្រះមហាគម្ពីរគួរអានត្រូវសរសេរជាភាសាអ្វី ?

ព្រះគម្ពីរគួរអានត្រូវសរសេរឡើងជាភាសាអារ៉ាប់ ។ ភាសាអារ៉ាប់សរសេរពីខាងស្តាំមកខាងឆ្វេង ។

## អល់ឡោះហ្ ﷻ មានព្រះរាជបន្ទូលថាអ្វីនៅក្នុងព្រះមហាគម្ពីរគួរអាន ?

អល់ឡោះហ្ ﷻ រៀបរាប់ប្រាប់នូវរឿងពិតរបស់ព្រះសាស្តានានា عليهم السلام ។

អល់ឡោះហ្ ﷻ ប្រាប់អំពីទង្វើដែលយើងត្រូវធ្វើ ។

អល់ឡោះហ្ ﷻ រៀបរាប់ប្រាប់យើងឲ្យដឹងអំពីឋានសួគ៌និងឋាននរក ។

អល់ឡោះហ្ ﷻ រៀបរាប់ប្រាប់យើងច្រើនរឿងណាស់ ។ យើងនឹងយល់រឿងមួយចំនួនពេលយើងធំបន្តិច ។ យើងនឹងយល់រឿងឯទៀតលុះត្រាយើងត្រឡប់ទៅឯ

ព្រះអង្គ﷿វិញ ព្រះអង្គ﷿នឹងពន្យល់ប្រាប់យើង ។

# ការគោរពព្រះមហាគម្ពីរគួរអាន

យើងត្រូវថែទាំព្រះមហាគម្ពីរគួរអានព្រោះវាជាសៀវភៅពិសេស ។ តើអ្នកត្រូវធ្វើម្តេច ?

យើងត្រូវកាន់ ចាប់ ឬប៉ះព្រះមហាគម្ពីរគួរអានដោយសេចក្តីគោរព (គ្រូត្រូវបង្ហាញសិស្ស) ។

យើងមិនត្រូវបើកព្រះមហាគម្ពីរគួរអានចោលជាដាច់ខាត បើពុំមានអ្នកណាសូត្រទេនោះ ។

យើងមិនត្រូវប៉ះតួអក្សរ (ហ្វ៊ុរុហ្វ اَلْحُرُوف) ព្រះមហាគម្ពីរគួរអានទេ បើពុំទាន់បានយកទឹកវូឌ្នុអ៍ជាមុនសិនទេនោះ ។ គេអាចសូត្រ (ឬអាន) ព្រះមហាគម្ពីរគួរអានបានដោយមិនប៉ះតួអក្សរ ឬដោយដាក់សន្លឹកផ្លាស្ទិចថ្លាទ្រាប់ពីលើសន្លឹកទំព័រព្រះមហាគម្ពីរគួរអាននោះបាន ។

ស៊ូណាត់ (អល់ឡោះហ្ស៍﷿សព្វព្រះហឫទ័យបើព្យាយាមធ្វើ) ពេលសូត្រព្រះមហាគម្ពីរគួរអាន គឺ៖

-គ្របក្បាល - ដោយមួកម្យ៉ាង(កន្តឹប)សម្រាប់ប្រុស ដោយក្រណាត់ទទូរក្បាលសម្រាប់ស្រី ។

-បែរមុខទៅរកគិ្ញបឡាត់ពេលគេសូត្រព្រះមហាគម្ពីរគួរអាន ។

យើងសូត្រថា អាអ៊ូស៊ូ ប៊ិលឡាហ៊ិ មីណាស្ស៊ៃត្វនីរ៉ជ៉ីម (أَعُوذُ بِاللهِ مِنَ الشَّيْطَانِ الرَّجِيمِ) និង ប៊ិសមិលឡាហ៊ិ រ៉ោះហ៊្មាំនីរ៉ហ៊ីម (بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ) មុនចាប់ផ្តើមសូត្រព្រះមហាគម្ពីរគួរអាន ។

# ការអនុវត្ត ១

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

أَعُوذُ بِاللَّهِ مِنَ اَلشَّيْطَانِ اَلرَّجِيمِ

*ខ្ញុំសូមជ្រកកោនក្រោមព្រះជម្រកអល់ឡោះហ្ជ៏ عز وجل ឲ្យចាកផុតមារស្ហៃតន لعنه الله ត្រូវបណ្តាសា*

២) ចូរអ្នកយកសន្លឹកផ្លាស្ទិចថ្លាមួយបន្ទះមកអនុវត្តិការប្រើប្រាស់ ហើយចូរដឹងថាហេតុអ្វីគេធ្វើបែបនេះ ។

៣) ចូរផាត់ពណ៌រូបក្នុងទំព័រទី ៤ គឺរូបត្ព៏លិបសូត្រគួរអានខាងលើ ហើយសរសេរឈ្មោះអ្នក (លោក/អ្នកគ្រូសរសេរឈ្មោះសិស្សជាភាសាអារ៉ាប់) ។

# សព្ទបច្ចេកទេស

-حَرْفٌ ហ្ារហ្វ៍ (ពហុវចនៈ حُرُوف ហ្ារុហ្វ) - តួអក្សរនៃព្យញ្ជនៈអារ៉ាប់ ។

-نُقْطَةٌ នុក្វតោះត៍ (ពហុវចនៈ نُقَط នុក្វត្ព៉) - ចំណុចពីលើឬពីក្រោមហ្ារុហ្វ ។

-حَرَكَةٌ ហ្ារ៉កាស៉ (ពហុវចនៈ حَرَكَات ហ្ារ៉កាត់) - សញ្ញាវណ្ណយុត្តសម្រាប់ប្រើផ្សំជាមួយហ្ារុហ្វ មាន៖

-ហ្វាត់ហ្ាស៉ (الفَتْحَةُ) ـَ

-កាស់រ៉ោះត៍ (الكَسْرَةُ) ـِ

-ឌុំម៉ាស៉ (الضَمَّةُ) ـُ

-مَخْرَجٌ ម៉ាក្ខ័រ៉ជ៉ុ (ពហុវចនៈ مَخَارِجُ ម៉ាខ៊ឺរីជ្ជុ) - របៀបថាឲ្យត្រូវតាមសម្លេងហ្វ៊ូរុហ្វ ។

# ការអនុវត្តិ ១

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

أَعُوذُ بِاللَّهِ مِنَ اَلشَّيْطَانِ اَلرَّجِيمِ

*ខ្ញុំសូមជ្រកកោនក្រោមព្រះជម្រកអល់ឡោះហ្ទ៏ﷻឲ្យចាកផុតមារស្ហៃតូនلعنه اللهត្រូវបណ្តាសា*

២) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

بِسْمِ اَللَّهِ اَلرَّحْمَٰنِ اَلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ្ទ៏ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី*

(សូមមើលសៀវភៅហ៊្វីក្ហោះហ្ទ៏ថ្នាក់ទី ១ មេរៀនទី ២)

៣) ចូរកាត់ក្រដាសរឹងងមួយបន្ទះតូចទ្រវែង ស្រួចមុខហើយផាត់ពណ៌បន្ទះក្រដាសនោះ ។ ប្រើបន្ទះក្រដាសនេះសម្រាប់សូត្រគូរអានជំនួសចង្អុលដៃ ។

**មេរៀនទី ២**

# ម៉ាខ៏រីច (مَخَارِجِ)

ម៉ាខ៏រីច (مَخَارِجِ) គឺប្រភពកំណើតនៃសម្លេងរបស់តួអក្សរ (គឺហ៊្វរុហ្វ) ។

ពេលហ៊្វរុហ្វមានហ្វាត់ហ៊ាស់ គឺសញ្ញាផ្តេកចោតនៅពីលើ បានសេចក្តីថាត្រូវបញ្ចេញសម្លេងហ៊្វរុហ្វនោះ ។

ហ៊្វរុហ្វច្រើនមានសម្លេងស្រដៀងគ្នា ។ ដូច្នេះអ្នកត្រូវដឹងថាមានសម្លេងចេញមកពីត្រង់ណា ត្រូវថាដូចម្តេច ។ អ្នកនឹងដឹងថាសម្លេងហ៊្វរុហ្វនោះខុសគ្នាដូចម្តេច ។

ហ៊្វរុហ្វបីតួខាងក្រោមនេះមានសម្លេងស្រដៀងគ្នាគឺៈ

-اَ

-عَ

-ءَ

ព្រោះតែហ៊្វរុហ្វទាំងបីនេះហាក់ដូចជាមានសម្លេងតែមួយ បានជាអ្នកត្រូវថាដោយប្រើប៉ែកផ្សេងៗរបស់មាត់អ្នក ដើម្បីនឹងឲ្យអ្នកស្តាប់ដឹងថាអ្នកថាហ៊្វរុហ្វមួយណា ។

-اَ ដាក់អណ្តាតផ្តេកនៅក្នុងមាត់ ។ សម្លេងកើតមកពីប៉ែកក្រោមរបស់បំពង់ក ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា អា ។

-عَ ដាក់អណ្តាតផ្តេកនៅក្នុងមាត់ ។ សម្លេងកើតមកពីខាងក្នុងរបស់មាត់ គឺកើតពីកណ្តាលបំពង់ក ឬកើតឡើងដោយតៀ្បតឬពង្រឹងដើមក ។ យើង

សរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា អ៊ុ ។

-ءَ សម្លេងចន្លោះ اَ និងង عَ ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា អ៊ុ ។

# ការអនុវត្តិ ២

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

قُلْ أَعُوْذُ بِرَبِّ النَّاسِ

*ចូរអ្នកថា៖ "ខ្ញុំសូមពឹងពាក់អាស្រ័យដោយសារព្រះម្ចាស់បណ្ដាមនុស្ស*

២) អ្នកគប្បីអាចអានបានមួយឃ្លាខាងក្រោមនេះគឺ៖

اَ عَ ءَ عَاَ عَ ءَ اَ عَ ءَ

៣) ចូរធ្វើលំហាត់ ១ ។ ចូរថាហ្វ៊ូរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្ដាំទៅខាងឆ្វេង) ។

# លំហាត់ ១

ចូរសរសេរលើរូបត៌្មលិបកន្លែងដែលជាប្រភពសម្លេងរបស់ហ្វ៊ូរុហ្វ ។



ចូរសរសេរដោយផ្ទិតផ្ទង់ហ្វ៊ូរុហ្វខាងក្រោមនេះ ៖

أَ

عَ

ءَ

## មេរៀនទី ៣

# ម៉ាខ៏រីច (مَخَارِج)

ចូររៀនសាឡើងវិញម៉ាខ៏រីចដែលបានរៀនរួចមកហើយ ។

ហ្ញរុហ្វច្រើនមានសម្លេងស្រដៀងគ្នា ។ ដូច្នេះអ្នកត្រូវដឹងរបៀបថាឲ្យត្រូវតាមសម្លេងហ្ញរុហ្វ ។ អ្នកនឹងដឹងថាសម្លេងហ្ញរុហ្វនោះខុសគ្នាដូចម្តេច ។

ហ្ញរុហ្វបីនេះមានសម្លេងស្រដៀងគ្នាគឺៈ

-تَ

-طَ

-ثَ

ព្រោះតែហ្ញរុហ្វទាំងបីនេះហាក់ដូចជាមានសម្លេងតែមួយ បានជាអ្នកត្រូវថាដោយប្រើប៉ែកផ្សេងៗរបស់មាត់អ្នក ដើម្បីនឹងឲ្យអ្នកស្តាប់ដឹងថាអ្នកថាហ្ញរុហ្វមួយណា ។

تَ ដាក់អណ្តាតអឹបនឹងពិតានមាត់ ពីខាងមុខធ្មេញមុខលើបន្តិច ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា តា ។

طَ ដាក់អណ្តាតអឹបនឹងពិតានមាត់ ហើយទម្លាក់អណ្តាតមកក្រោមយ៉ាងលឿន សម្លេងចេញមកពីក្រអូមមាត់ ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ត៏ ។

ثَ ដាក់អណ្តាតត្រង់ចន្លោះធ្មេញមុខលើនិងធ្មេញក្រោម វាមានសម្លេងដូចអក្សរអង់គ្លេស "th" ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ស្ធ ។

# ការអនុវត្ត ៣

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

مَلِكِ النَّاسِ

*ព្រះមហាក្សត្ររបស់បណ្តាមនុស្ស*

إِلَٰهِ النَّاسِ

*ព្រះរបស់បណ្តាមនុស្ស*

២) អ្នកគប្បីអាចអានបានមួយឃ្លាខាងក្រោមនេះគឺៈ

اَ عَ ءَ تَطَثَتَطَثَطَتَثَ

៣) ចូរធ្វើលំហាត់ ២ ។ ចូរថាហ្វ៊ូរហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្តាំទៅខាងឆ្វេង) ។

## លំហាត់ ២

ចូរសរសេរលើរូបគំនូសលិបកន្លែងដែលជាប្រភពសម្លេងរបស់ហ្វ៊ូរុហ្វ ។





ثَ طَ تَ

ចូរសរសេរដោយផ្ទិតផ្ទង់ហ្វ៊ូរុហ្វខាងក្រោមនេះ ៖

تَ تَ تَ

طَ طَ طَ

ثَ ثَ ثَ

## មេរៀនទី ៤

# ម៉ាខ៏រីច្ញ (مَخَارِج)

ចូររៀនសាឡើងវិញម៉ាខ៏រីច្ញដែលបានរៀនរួចមកហើយ ។

ហ៊្វរុហ្វច្រើនមានសម្លេងស្រដៀងគ្នា ។ ដូច្នេះអ្នកត្រូវដឹងរបៀបថាឲ្យត្រូវតាមសម្លេងហ៊្វរុហ្វ ។ អ្នកនឹងដឹងថាសម្លេងហ៊្វរុហ្វនោះខុសគ្នាដូចម្ដេច ។

ហ៊្វរុហ្វបីនេះមានសម្លេងស្រដៀងគ្នាគឺ៖

-سَ

-صَ

-زَ

ព្រោះតែហ៊្វរុហ្វទាំងបីនេះហាក់ដូចជាមានសម្លេងតែមួយ បានជាអ្នកត្រូវថាដោយប្រើប៉ែកផ្សេងៗរបស់មាត់អ្នក ដើម្បីនឹងឲ្យអ្នកស្ដាប់ដឹងថាអ្នកថាហ៊្វរុហ្វមួយណា ។

سَ ដាក់អណ្ដាតផ្ដេក បញ្ចេញខ្យល់តាមចន្លោះពិតានមាត់និងអណ្ដាតបន្តិច ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា សា ។

صَ ដាក់ចុងអណ្ដាតអឹបនឹងពិតានមាត់ ហើយទម្លាក់អណ្ដាតមកក្រោមឲ្យលឿន ពោលគឺ សម្លេងចេញមកពីក្រអូមមាត់ ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ស្វ៏ ។

زَ ចុងអណ្ដាតប៉ះពិតានមាត់ គឺមានសម្លេង "ស" គ្បៀតដូចអក្សរអង់គ្លេស "Z" ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ស្ហ៊ា ។

# ការអនុវត្តិ ៤

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

مِنْ شَرِّ الْوَسْوَاسِ الْخَنَّاسِ

*ឲ្យបានចាកផុតពីអំពើអាក្រក់របស់អ្នកលបខ្សឹបខ្សៀវ*

២) អ្នកគប្បីអាចអានបានមួយឃ្លាខាងក្រោមនេះគឺៈ

اَ عَ ءَ تَطَثَتَسَصَزَصَسَزَصَ

៣) ចូរធ្វើលំហាត់ ៣ ។ ចូរថាហ្ជូរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្តាំទៅខាងឆ្វេង) ។

## លំហាត់ ៣

ចូរសរសេរលើរូបត្ត៏លិបកន្លែងដែលជាប្រភពសម្លេងរបស់ហ៊្វូរុហ្វ ។







سَ صَ زَ

ចូរសរសេរដោយផ្ទិតផ្ទង់ហ៊្វូរុហ្វខាងក្រោមនេះ ៖

سَ سَ سَ

صَ صَ صَ

زَ زَ زَ

## មេរៀនទី ៥

# ម៉ាខ៉ូរីច (مَخَارِج)

ចូររៀនសាឡើងវិញម៉ាខ៉ូរីចដែលបានរៀនរួចមកហើយ ។

ហ៊ូរុហ្វច្រើនមានសម្លេងស្រដៀងគ្នា ។ ដូច្នេះអ្នកត្រូវដឹងរបៀបថាឲ្យត្រូវតាមសម្លេងហ៊ូរុហ្វ ។ អ្នកនឹងដឹងថាសម្លេងហ៊ូរុហ្វនោះខុសគ្នាដូចម្ដេច ។

ហ៊ូរុហ្វបីនេះមានសម្លេងស្រដៀងគ្នាគឺ៖

-ذَ

-ظَ

-ضَ

ព្រោះតែហ៊ូរុហ្វទាំងបីនេះហាក់ដូចជាមានសម្លេងតែមួយ បានជាអ្នកត្រូវថាដោយប្រើប៉ែកផ្សេងៗរបស់មាត់អ្នក ដើម្បីនឹងឲ្យអ្នកស្ដាប់ដឹងថាអ្នកថាហ៊ូរុហ្វមួយណា ។

ذَ -ដាក់អណ្ដាតចន្លោះធ្មេញលើនិងធ្មេញក្រោម ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ស្មា ។

ظَ -ដាក់អណ្ដាតអឹបនឹងពិតានមាត់ ហើយទម្លាក់អណ្ដាតមកក្រោមឲ្យលឿន ពោលគឺ សម្លេងចេញមកពីក្រអូមមាត់ ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ស្ន៎ ។

ضَ -ដាក់អណ្ដាតអឹបនឹងពិតានមាត់ ហើយទម្លាក់អណ្ដាតមកក្រោមឲ្យលឿន ពោលគឺ សម្លេងចេញមកពីក្រអូមមាត់ ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ដ្ន៎ ។

# ការអនុវត្តិ ៥

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

الَّذِي يُوَسْوِسُ فِي صُدُوْرِ النَّاسِ

*ដែលខ្សឹបខ្សៀវនៅក្នុងទ្រូងបណ្តាមនុស្ស*

២) អ្នកគប្បីអាចអានបានមួយឃ្លាខាងក្រោមនេះគឺៈ

اَ عَ ءَ تَطَثَسَصَزَذَظَضَذَضَظَضَ

៣) ចូរធ្វើលំហាត់ ៤ ។ ចូរថាហ្ស៊ូរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្តាំទៅខាងឆ្វេង) ។

## លំហាត់ ៤

ចូរសរសេរលើរូបត្ត៏លិបកន្លែងដែលជាប្រភពសម្លេងរបស់ហ្វ៊ូរុហ្វ ។







ضَ ظَ ذَ

ចូរសរសេរដោយផ្ទិតផ្ទង់ហ្វ៊ូរុហ្វខាងក្រោមនេះ ៖

ذَ ذَ ذَ

ظَ ظَ ظَ

ضَ ضَ ضَ

## មេរៀនទី ៦

# ម៉ាខ៌រីច (مَخَارِج)

ចូររៀនសាឡើងវិញម៉ាខ៌រីចដែលបានរៀនរួចមកហើយ ។

ហ៊្វរុហ្វច្រើនមានសម្លេងស្រដៀងគ្នា ។ ដូច្នេះអ្នកត្រូវដឹងរបៀបថាឲ្យត្រូវតាមសម្លេងហ៊្វរុហ្វ ។ អ្នកនឹងដឹងថាសម្លេងហ៊្វរុហ្វនោះខុសគ្នាដូចម្តេច ។

ហ៊្វរុហ្វពីរតួនេះមានសម្លេងស្រដៀងគ្នាគឺ៖

-هَ

-حَ

ព្រោះតែហ៊្វរុហ្វទាំងពីរនេះហាក់ដូចជាមានសម្លេងតែមួយ បានជាអ្នកត្រូវថាដោយប្រើប៉ែកផ្សេងៗរបស់មាត់អ្នក ដើម្បីនឹងឲ្យអ្នកស្តាប់ដឹងថាអ្នកថាហ៊្វរុហ្វមួយណា ។

هَ -សម្លេងអក្សរ ហ បញ្ចេញខ្យល់មកពីប៉ែកក្រោមនៃបំពង់ក លើដើមទ្រូង ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ហា ។

حَ -សម្លេងអក្សរ ហ បញ្ចេញខ្យល់មកពីប៉ែកលើនៃបំពង់កដោយតឿត ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ហា ។

# ការអនុវត្ត ៦

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរនិងយល់ន័យរបស់

مِنَ الْجِنَّةِ وَالنَّاسِ

*ក្នុងចំណោមពួកយ៉ិននិងពួកមនុស្ស ។*

២) អ្នកគប្បីអាចអានបានមួយឃ្លាខាងក្រោមនេះគឺៈ

اَ عَ ءَ تَطَشَسَصَزَذَظَضَهَحَهَحَهَ

៣) ចូរធ្វើលំហាត់ ៥ ។ ចូរថាហ្ញ៉ុរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្តាំទៅខាងឆ្វេង) ។

# លំហាត់ ៥

ចូរសរសេរលើរូបត៌្បលិបកន្លែងដែលជាប្រភពសម្លេងរបស់ហ្វ៊ុរុហ្វ ។



ចូរសរសេរដោយផ្ទិតផ្ទង់ហ្វ៊ុរុហ្វខាងក្រោមនេះ ៖

هَ هَ هَ

خَ خَ خَ

## មេរៀនទី ៧

# ម៉ាខ៏រីច (مَخَارِج)

ចូររៀនសាឡើងវិញម៉ាខ៏រីច្ចដែលបានរៀនរួចមកហើយ ។

ហ៊្វរុហ្វច្រើនមានសម្លេងស្រដៀងគ្នា ។ ដូច្នេះអ្នកត្រូវដឹងរបៀបថាឲ្យត្រូវតាមសម្លេងហ៊្វរុហ្វ ។ អ្នកនឹងដឹងថាសម្លេងហ៊្វរុហ្វនោះខុសគ្នាដូចម្តេច ។

ហ៊្វរុហ្វបួនតួនេះមានសម្លេងស្រដៀងគ្នាគឺៈ كَ, قَ, خَ, غَ ។

ព្រោះតែហ៊្វរុហ្វទាំងបីនេះហាក់ដូចជាមានសម្លេងតែមួយ បានជាអ្នកត្រូវថាដោយប្រើប៉ែកផ្សេងៗរបស់មាត់អ្នក ដើម្បីនឹងឲ្យអ្នកស្តាប់ដឹងថាអ្នកថាហ៊្វរុហ្វមួយណា ។

- كَ -សម្លេងចេញមកពីប៉ែកលើនៃបំពង់កតែស្រាល ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា កា ។
- قَ -សម្លេងចេញមកពីប៉ែកក្រោយនៃក្រអូមមាត់ ដោយទម្លាក់អណ្តាតមកក្រោមឲ្យលឿន ឬ ពង្រឹងប៉ែកក្រោយនៃក្រអូម (ឬប៉ែកលើនៃបំពង់ក) ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ក៏្វ ឬ ក៏ ។
- خَ -សម្លេងតួអក្សរនេះប្រៀបបាននឹងពេលអ្នកខាក ពោលគឺ គៀតប្រអូមមាត់ ឬពង្រឹងប៉ែកក្រោយនៃក្រអូមមាត់ (ឬប៉ែកលើនៃបំពង់ក) ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ខ៏្ ឬ ខ៏ ។
- غَ -សម្លេងចេញមកពីប៉ែកក្រោយនៃក្រអូមមាត់ ដោយទម្លាក់អណ្តាតមកក្រោមឲ្យលឿន ឬ ពង្រឹងប៉ែកក្រោយនៃក្រអូម (ឬប៉ែកលើនៃបំពង់ក) ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា ក៏្ ។

# ការអនុវត្តិ ៧

១) ចូរសិក្សាសាឡើងវិញឲ្យចាំរត់មាត់ត្រឹមត្រូវតាមអក្សរ ស្វរ៉េះត្ញ៉ អាន់-ណាស់ ។

قُلْ أَعُوْذُ بِرَبِّ النَّاسِ

مَلِكِ النَّاسِ

إِلٰهِ النَّاسِ

مِنْ شَرِّ الْوَسْوَاسِ الْخَنَّاسِ

الَّذِيْ يُوَسْوِسُ فِيْ صُدُوْرِ النَّاسِ

مِنَ الْجِنَّةِ وَالنَّاسِ

២) អ្នកគប្បីអាចអានបានមួយឃ្លាខាងក្រោមនេះគឺៈ

اَ عَ ءَ تَطَثَسَصَزَذَظَضَهَحَكَقَخَغَقَكَخَغَخَقَكَ

៣) ចូរធ្វើលំហាត់ ៦ ។ ចូរថាហ៊្វរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្ដាំទៅខាងឆ្វេង) ។

# លំហាត់ ៦

ចូរសរសេរលើរូបតំលិបកន្លែងដែលជាប្រភពសម្លេងរបស់ហ៊្វរុហ្វ ។



ចូរសរសេរដោយផ្ទិតផ្ទង់ហ៊្វរុហ្វខាងក្រោមនេះ ៖

كَ كَ كَ

قَ قَ قَ

خَ خَ خَ

غَ غَ غَ

## មេរៀនទី ៨

# ម៉ាខ៉ូរីច (مَخَارِج)

ចូររៀនសាឡើងវិញម៉ាខ៉ូរីចដែលបានរៀនរួចមកហើយ ។

ហ៊ូរុហ្វទាំងនេះយើងមិនទាន់បានសិក្សានៅឡើយទេ តែរបៀបថានិងរបៀបបញ្ចេញសម្លេងដូចគ្នា គឺៈ

ب មានសម្លេងស្មើអក្សរ ប ។

ج មានសម្លេងស្មើអក្សរ យ (បើថាឲ្យត្រូវគឺ "ដ្យ" ដូចភាសាអង់គ្លេស "dj" ឬ "j" ។ តែយើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា "ឃ្ជ" ។

ذ មានសម្លេងស្មើអក្សរ ដ ប្រឡោះធ្មេញដូចភាសាអង់គ្លេស "th" ។ តែយើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា "ដ្វ" ។

ر មានសម្លេងស្មើអក្សរ រ ។

ش មានសម្លេងស្មើអក្សរ ស ដោយបញ្ចេញខ្យល់តាមចន្លោះតូចនៃពិតានមាត់និងអណ្តាត ដូចភាសាអង់គ្លេស "sh" ។ យើងសរសេរជាភាសាខ្មែរឲ្យត្រូវតាមសម្លេងអារ៉ាប់ថា "ស្ជ" ។

ه មានសម្លេងស្មើអក្សរ ហ្វ ដោយបញ្ចេញខ្យល់ ។

ل មានសម្លេងស្មើអក្សរ ល ឬ ឡ ។

م មានសម្លេងស្មើអក្សរ ម ។

ن មានសម្លេងស្មើអក្សរ ន ឬ ណ ។

و មានសម្លេងស្មើអក្សរ វ ។

ي មានសម្លេងស្មើអក្សរ យ ។

# ការអនុវត្តិ ៨

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរនិងយល់ន័យរបស់

قُلْ أَعُوْذُ بِرَبِّ الْفَلَقِ

*ចូរអ្នកថាៈ "ខ្ញុំសូមជ្រកកោនក្រោមជម្រកព្រះម្ចាស់លោហិតារុណ*

២) ចូរហ្វឹកហាត់ថាឮៗហ្ញ៊ូរុហ្វនៅក្នុងព្រះមហាគម្ពីរគួរអាន ។ សិស្សត្រូវចេះស្ទាត់ម៉ាក់រ៉ច់បាន ៧៥% ។

៣) ចូរធ្វើលំហាត់ ៧ ។ ចូរថាហ្ញ៊ូរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្តាំទៅខាងឆ្វេង) ។

## លំហាត់ ៧

ចូរសរសេរនៅពីមុខព្រួញ ហ៊ូរុហ្វដោយដាក់ហ្វាត់ហ៊ាស៊ូ ដែលត្រូវនឹងសម្លេងអក្សរខ្មែរលើផ្លែព្រួញ ។



## មេរៀនទី ៩

ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ និងយល់ន័យរបស់

مِنْ شَرِّ مَا خَلَقَ

*ឲ្យបានផុតចាកពីអំពើអាក្រក់បណ្ដាលមកពីអ្វីដែលព្រះអង្គបានបង្កើតមក*

មេរៀននេះមានគោលបំណងពិនិត្យមើលថាសិស្សទាំងអស់គ្នាស្គាល់ និងចាំរត់មាត់ម៉ាខ៏រីច្ចទាំងអស់នៃព្យញ្ជនៈអារ៉ាប់ដោយមិនបាច់មានគេជួយប្រាប់ ។

សិស្សទាំងអស់គ្នាត្រូវអាចអានហ៊្វរុហ្វទាំងអស់បានយ៉ាងស្ទាត់ត្រូវម៉ាខ៏រីច្ច ។

ចូរធ្វើលំហាត់ ៨ (សិស្សត្រូវធ្វើលំហាត់ត្រឹមត្រូវលើសពី ៧៥%) ។

បើសិស្សណាមិទាន់ចេះស្ទាត់ម៉ាខ៏រីច្ចណាមួយទេ ដែលបានរៀនមកដល់ពេលនេះ ត្រូវផ្ញើសំបុត្រទៅឪពុកម្ដាយសិស្សនោះដោយបញ្ជាក់ប្រាប់នូវសេចក្ដីត្រូវការរបស់សិស្ស គឺ៖

ជូនចំពោះឪពុកម្ដាយសិស្ស

យើងខ្ញុំបានបង្ហាត់បង្រៀនកូនលោកអ្នកនូវម៉ាខ៏រីច្ចទាំងអស់នៃព្យញ្ជនៈអារ៉ាប់ តែពេលប្រលងកូនលោកអ្នកមានបញ្ហាខ្លះខាងក្រោមនេះ គឺ៖

(ប្រាប់បញ្ហាដែលសិស្សជួបប្រទះអំពីម៉ាខ៏រិច្ច)

សូមលោកឪពុកអ្នកម្ដាយជួយបំពេញកង្វះខាងលើនេះសម្រាប់អាទិត្យក្រោយ ។

جَزَاكَ ٱللَّٰهُ

## លំហាត់ ៨

ចូរថាហ្ស៊ុរុហ្វនីមួយៗដែលនៅក្នុងប៊ីតប៉ោងឲ្យគ្រូស្តាប់ ដើម្បីនឹងដឹងថាតើគ្រូស្តាប់យល់អ្នកថាហ្ស៊ុរុហ្វអ្វីទេ ។ រួចហើយចូរស្តាប់គ្រូថាវិញ ។




ចូរគូសខ្សែប៊ីតប៉ោងទាំងអស់ ។



**មេរៀនទី ១០**

# កាស់រ៉ោះត៍ (اَلْكَسْرَةُ)

កាស់រ៉ោះត៍ (اَلْكَسْرَةُ) គឺវណ្ណយុត្តមួយដែលមានសណ្ឋានបញ្ឆិតផ្ដេកដាក់ពីក្រោមហ៊ូរុហ្វ ـِـ ។

ពេលអ្នកឃើញវណ្ណយុត្តនេះនៅពីក្រោមហ៊ូរុហ្វ អ្នកត្រូវថាហ៊ូរុហ្វនោះជាមួយស្រៈ "អ៊ិ"

ឧទាហរណ៍ បា + កាស់រ៉ោះត៍ بِ = ប + អ៊ិ = ប៊ិ ។

ចូរដឹងថាវាមានសម្លេងខ្លីដូចពាក្យ "ស៊ិ, ជិ, ញ៊ិ" ជាដើម ។

## ការអនុវត្ត ១០

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរនិងយល់ន័យរបស់

وَمِنْ شَرِّ غَاسِقٍ إِذَا وَقَبَ

*ឲ្យបានផុតចាកពីអំពើអាក្រក់របស់ភាពងងឹតពេលវាមកដល់*

២) ចូរហ្វឹកហាត់ថាឮៗហ៊ូរុហ្វនៅក្នុងព្រះមហាគម្ពីរគួរអាន ។ សិស្សត្រូវចេះស្ទាត់ត្រូវម៉ាខ៏រីចុលើសពី ៧៥% ។

៣) ចូរធ្វើលំហាត់ ៩ ។ ចូរថាហ៊ូរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្ដាំទៅខាងឆ្វេង) ។

## លំហាត់ ៩

ចូរចាំថាពេលហ្វ៊ូរុហ្វជួបកាស់រ៉េះត៌្ អ្នកត្រូវថាដោយមានសម្លេង "អ៊ី" ជាមួយហ្វ៊ូរុហ្វ (ដូចពេលគេញញឹម) ។

ចូរផាត់ពណ៌មាត់ញញឹម ហើយសរសេរហ្វ៊ូរុហ្វខ្លះដាក់កាស់រ៉េះត៌្ ។



**មេរៀនទី ១១**

## ដុំម៉ាស់ (اَلضَّمَّةُ)

គេហៅសញ្ញារង្វង់មូលមានកូនជើងនៅពីលើហ៊្វរុហ្វថា ដុំម៉ាស់ ـُ ។

ពេលអ្នកឃើញវណ្ណយុត្តនេះ អ្នកត្រូវថាហ៊្វរុហ្វដោយធ្វើមាត់មូលដូចរង្វង់មូលជាមួយសម្លេង "អ៊ូ" ។

ឧទាហរណ៍ បា + ដុំម៉ាស់ بُ = ប + អ៊ូ = ប៊ូ ។

ចូរដឹងថាវាមានសម្លេងខ្លីដូចពាក្យថា "លូ, ធូរ" ជាដើម ។

## ការអនុវត្ត ១១

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរនិងយល់ន័យរបស់

وَمِنْ شَرِّ النَّفَّاثَاتِ فِيْ الْعُقَدِ

*ឲ្យបានផុតចាកពីអំពើអាក្រក់របស់បណ្ដាអ្នកផ្លុំលើចំណង*

២) ចូរហ្វឹកហាត់ថាឮៗហ៊្វរុហ្វនៅក្នុងព្រះមហាគម្ពីរគួរអាន ។ សិស្សត្រូវចេះស្ទាត់ត្រូវម៉ាខ៌រីជ្ជលើសពី ៧៥% ។

៣) ចូរធ្វើលំហាត់ ១០ ។ ចូរថាហ៊្វរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្ដាំទៅខាងឆ្វេង) ។

# លំហាត់ ១០

ចូរចាំថាពេលហ្វ៊ូរុហ្វជួបដំម៉ាស្ញ់ អ្នកត្រូវថាដោយធ្វើមាត់មូលដូចរង្វង់មូលជាមួយសម្លេង "អ៊ូ" ។ ។

ចូរផាត់ពណ៌រូបតុ៏លិបបង្ហាញធ្វើសម្លេង "អ៊ូ" ហើយចូរសរសេរហ្វ៊ូរុហ្វខ្លះដាក់ដំម៉ាស្ញ់ ។



# លំហាត់ ១១

ចូរគូរមាត់ត្ច័លិបពេលវាថាហ្ជ៊ុរុហ្វមានហ្វាត់ហ្ចាស្ញ់ ពេលថាហ្ជ៊ុរុហ្វមានកាស់រ៉ោះត្ញ័ ពេលថាហ្ជ៊ុរុហ្វមានដ្ធំម៉ាស្ញុំ ។



ហ្ជ៊ុរុហ្វមានហ្វាត់ហ្ចាស្ញ់



ហ្ជ៊ុរុហ្វមានកាស់រ៉ោះត្ញ័



ហ្ជ៊ុរុហ្វមានដ្ធំម៉ាស្ញុំ

ចូរសរសេរអក្សរអារ៉ាប់ឲ្យត្រូវនឹងអក្សរខ្មែរ ។

| | | | |
|---|---|---|---|
| បា - | ឃ្ជុ - | មី - | ស្ថា - |
| ឃ្ជូ - | ហ្វ៊ី - | ប៊ី - | លូ - |
| សា - | ឌ្វី - | ស្ឝូ - | ណា - |
| ប៊ូ - | រ៉ - | ត្ដី - | ឌ្ឍី - |
| ទូ - | រ្វ - | ស៊ី - | ឌ្ធូ - |
| រី - | ឡ្សា - | ហ្វា - | ស្ឝី - |

## មេរៀនទី ១២

# រៀនសាឡើងវិញ

មេរៀននេះមានគោលបំណងពិនិត្យមើលថាសិស្សទាំងអស់គ្នាស្គាល់ និងចាំរត់មាត់ម៉ាខ៌រីច្ចទាំងអស់នៃព្យញ្ជនៈអារ៉ាប់ដោយមិនបាច់មានគេជួយប្រាប់ ។

សិស្សទាំងអស់គ្នាត្រូវអាចអានហ៊្វរុហ្វទាំងអស់បានយ៉ាងស្ទាត់ត្រូវម៉ាខ៌រីច្ច ។

ចូរធ្វើលំហាត់ ១១ (សិស្សត្រូវធ្វើលំហាត់ត្រឹមត្រូវលើសពី ៧៥%) ។

បើសិស្សចេះស្ទាត់ម៉ាខ៌រីច្ចហ៊្វរុហ្វទាំងអស់ជាមួយហារ៉កាត់ហើយ ពោលគឺ ចេះអានត្រឹមត្រូវ ហើយបានធ្វើលំហាត់ ១១ ហើយ គេអាចប្រគល់ **សញ្ញាបត្រ អាស់សាស់រ៉អុំ គូរអាន ២** ឲ្យសិស្សនោះ ។

បើសិស្សមិនជាប់សញ្ញាបត្រ **សញ្ញាបត្រ អាស់សាស់រ៉អុំ** ទេ ត្រូវផ្ញើសំបុត្រទៅឪពុកម្ដាយសិស្សដោយបញ្ជាក់ប្រាប់នូវបញ្ហាដែលសិស្សជួបប្រទះ គឺ៖

| |
|---|
| ជូនចំពោះឪពុកម្ដាយសិស្ស<br><br>យើងខ្ញុំបានបង្ហាត់បង្រៀនកូនលោកអ្នកនូវម៉ាខ៌រីច្ចទាំងអស់នៃព្យញ្ជនៈអារ៉ាប់ តែពេលប្រលងកូនលោកអ្នកនៅមានបញ្ហាខ្លះខាងក្រោមនេះ គឺ៖<br><br>(ប្រាប់បញ្ហាដែលសិស្សជួបប្រទះអំពីម៉ាខ៌រីច្ច)<br><br>សូមលោកឪពុកអ្នកម្ដាយជួយបំពេញកង្វះខាងលើនេះសម្រាប់អាទិត្យក្រោយ ។<br><br>جَزَاكَ ٱللَّهُ |

## មេរៀនទី ១៣

# ស៊ូគូន (اَلسُّكُونُ)

គេហៅសញ្ញារង្វង់មូល ْ ឬ មួយចំហៀងមូល ْ នៅពីលើហ៊្វរុហ្វថា ស៊ូគូន ។

ពេលអ្នកឃើញវណ្ណយុត្តនេះ អ្នកត្រូវភ្ជាប់វណ្ណយុត្តនេះជាមួយហ៊្វរុហ្វដែលនៅពីមុខ (គឺនៅខាងស្តាំ) វណ្ណយុត្តនេះ ។ ស៊ូគូនប្រៀបបាននឹងការ (បាយម៉ាន) ។

ឧទាហរណ៍ "តា" ដាក់ហ្វាត់ហ៊ាស្ម មាន "បា" ជាប់តាមក្រោយដាក់ស៊ូគូន គឺៈ តា + បា ដាក់ ស៊ូគូន = តាប់; تَبْ = بْ + تَ ។

ហ៊្វរុហ្វមិនចាប់ផ្តើមដោយមានស៊ូគូនជាដាច់ខាត ។

ហ៊្វរុហ្វដែលមានស៊ូគូននោះតោងជាប់ហ៊្វរុហ្វដែលនៅពីមុខវា ដូច្នេះហ៊្វរុហ្វដែលនៅពីមុខហ៊្វរុហ្វមានស៊ូគូននោះត្រូវតែមានហ៊ារ៉កាត់ជាចាំបាច់ (គឺមានហ្វាត់ហ៊ាស្ម មានកាស់រ៉ោះត៍ មានដុំម៉ាស្ម) ។

# ការអនុវត្តិ ១៣

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរនិងយល់ន័យរបស់

وَمِنْ شَرِّ حَاسِدٍ إِذَا حَسَدَ

*ឲ្យបានផុតចាកពីអំពើអាក្រក់របស់ឥច្ឆាបកតបុគ្គល (គឺអ្នកច្រណែនឈ្នានីស) ពេលវាឥច្ឆា ។*

២) ចូរហ៊ឹកហាត់ថាឮៗហ៊្វរុហ្វនៅក្នុងព្រះមហាគម្ពីរគួរអាន ។ សិស្សត្រូវចេះស្ទាត់ត្រូវម៉ាខ៌ារីច្ចលើសពី ៧៥% ។

៣) ចូរធ្វើលំហាត់ ១២ ។ ចូរថាហ្វ៊ូរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្តាំទៅខាងឆ្វេង) ។

## លំហាត់ ១២

ស្វ៊ូគូនប្រៀបបាននឹង




ចូរផ្គុំហ្វ៊ូរុហ្វមានហ្វារ៉កាត់ជាមួយហ្វ៊ូរុហ្វមានស្វ៊ូគូន ។ បន្ទាប់មកចូរសរសេរ លទ្ធផលដែលបានពីការផ្គុំហ្វ៊ូរុហ្វទាំងនេះ រួចហើយបង្ហាញគ្រូ ។

ثْ + اَ ←——

لْ + عِ ←——

كْ + ضُ ←——

قْ + بُ ←——

حْ + شِ ←——

عْ + دُ ←——

**មេរៀនទី ១៤**

# តាន់វីន (تَنْوِيْنٌ)

គេហៅហ្ការ៉កាត់ពីរដូចគ្នា (ហ្វាត់ហ្ហាស្ទុំពីរ, កាស់រ៉ោះត្ទ័ពីរ, ដ្ហុំម៉ាស្ទុំពីរ) នៅពីលើហ្វ៊ូរុហ្វថា តាន់វីន ។

ពេលអ្នកឃើញតាន់វីនពីលើហ្វ៊ូរុហ្វ អ្នកត្រូវបន្ថែមសម្លេង អាន់ ឬ អ៊ីន ឬ អ៊ុន ។

តាន់វីនប្រៀបបាននឹងនូនស្វ៊ូគូនបូកនឹងហ្វ៊ូរុហ្វ ។ ។

ឧទាហរណ៍៖

បា ដាក់តាន់វីនដ្ហុំម៉ាស្ទុំ بُنْ = بٌ

បា ដាក់តាន់វីនកាស់រ៉ោះត្ទ័ បِنْ = بٍ

បា ដាក់តាន់វីនហ្វាត់ហ្ហាស្ទុំ بَنْ = بًا

ចូរកត់សម្គាល់ថា ពេលសរសេរតាន់វីនហ្វាត់ហ្ហាស្ទុំត្រូវតែមានអាលិហ្វពីក្រោយជាចាំបាច់ លើកលែងតែតាន់វីនហ្វាត់ហ្ហាស្ទុំពីលើហ្វ៊ូរុហ្វ "តា មារប៊ូត្មោះត្ទ័ (ة)" (تَاء مَرْبُوطَة) ةَنْ = ةً ។ អាលិហ្វនេះមិនធ្វើឲ្យមានសម្លេងវែងទេ ។

# ការអនុវត្ត ១៤

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរ ស្វ៊ូរ៉ោះត្ទ័ អាល់-ហ្វាឡាក្ទ័

قُلْ أَعُوذُ بِرَبِّ الْفَلَقِ

مِنْ شَرِّ مَا خَلَقَ

مِنْ شَرِّ غَاسِقٍ إِذَا وَقَبَ

وَمِنْ شَرِّ النَّفَّاثَاتِ فِي الْعُقَدِ

وَمِنْ شَرِّ حَاسِدٍ إِذَا حَسَدَ

២) ចូរហ្វឹកហាត់ថាឮៗហ្វ៊ូរុហ្វនៅក្នុងព្រះមហាគម្ពីរគួរអាន ។ សិស្សត្រូវចេះស្ទាត់ត្រូវម៉ាខ៌ររីច្ចលើសពី ៧៥% ។

៣) ចូរធ្វើលំហាត់ ១៣ ។ ចូរថាហ្វ៊ូរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្តាំទៅខាងឆ្វេង) ។

# លំហាត់ ១៣

ហ៊្វរុហ្វដាក់ហ្ការ៉កាត់ជួប នូនស៊ូគូន (نْ) ដូចហ៊្វរុហ្វដាក់តាន់វីនដែរ ។ ចូរសរសេរដោយដាក់តាន់វីន ។



**មេរៀនទី ១៥**

# តាស្ឌ៉ីដ (تَشْدِيْد) ឬ ស្ឋាដ់ដាស់ (شَدَّة)

គេហៅសញ្ញាវណ្ណយុត្តមួយនេះ ّ នៅពីលើហ្វ៊ូរុហ្វថា តាស្ឌ៉ីដ តែយើងហៅជាសាមញ្ញថា ស្ឋាដ់ដាស់ ។

ពេលអ្នកឃើញតាស្ឌ៉ីដនៅពីលើហ្វ៊ូរុហ្វណា អ្នកត្រូវថែមហ្វ៊ូរុហ្វនោះមួយជាពីរ ដោយដាក់ស៊ូគូនលើហ្វ៊ូរុហ្វទីមួយ ដាក់ហ្ការ៉កាត់លើហ្វ៊ូរុហ្វទីពីរ យកហ្វ៊ូរុហ្វទីពីរនេះជាហ្វ៊ូរុហ្វដើមដែលមានតាស្ឌ៉ីដ ។

ឧទាហរណ៍ ៖

អាលិហ្វជាមួយហ្វាត់ហ្ការស់ បាជាមួយហ្វាត់ហ្ការស់ តាស្ឌ៉ីដ ៖

اَبَّ = اَبْبَ

អាលិហ្វជាមួយហ្វាត់ហ្ការស់ បាជាមួយកាស់រ៉ោះត៍ តាស្ឌ៉ីដ ៖

اَبِّ = اَبْبِ

អាលិហ្វជាមួយហ្វាត់ហ្ការស់ បាជាមួយដ្ហុំម៉ាស់ តាស្ឌ៉ីដ ៖

اَبُّ = اَبْبُ

## ការអនុវត្ត ១៥

១) ចូរអ្នកសិក្សាឲ្យចាំរត់មាត់របៀបសូត្រឲ្យត្រឹមត្រូវតាមអក្សរនិងយល់ន័យរបស់

إِنَّا أَعْطَيْنَاكَ الْكَوْثَرَ

*ពិតណាស់ យើងបានប្រទានអាល់-កៅស្សារឲ្យអ្នក ។*

២) ចូរហ្វឹកហាត់ថាឮៗហ៊្វរុហ្វនៅក្នុងព្រះមហាគម្ពីរគួរអាន ។ សិស្សត្រូវចេះស្ទាត់ត្រូវម៉ាខ៌រីច្ចលើសពី ៧៥% ។

៣) ចូរធ្វើលំហាត់ ១៤ ។ ចូរថាហ៊្វរុហ្វសាចុះសាឡើងព្រមនឹងសរសេរ (ពីខាងស្ដាំទៅខាងឆ្វេង) ។

## លំហាត់ ១៤

ចូរសរសេរហារ៉ាកាត់ត្រឹមត្រូវពីលើហ៊្វរុហ្វគ្រប់តួ ហើយផាត់ពណ៌ឡាន ។















## មេរៀនទី ១៦

# ស៊ូរ៉ោះត៊ុ អាល់-ហ្វាទីហាស់ - ទន្ទេញចាំរត់មាត់ - តាហ្សៀរ

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ៊្វ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

اَلْحَمْدُ لِلّٰهِ رَبِّ الْعَالَمِيْنَ

*សូមថ្វាយសេចក្តីសរសើរចំពោះអល់ឡោះហ៊្វ ﷻ ព្រះម្ចាស់ពិភពទាំងពួង*

الرَّحْمٰنِ الرَّحِيْمِ

*ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី*

مَالِكِ يَوْمِ الدِّيْنِ

*ព្រះម្ចាស់នៃថ្ងៃជំនុំជម្រះ*

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِيْنُ

*ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំគោរពបូជា ព្រះអង្គទេដែលអស់ទូលព្រះបង្គំជាខ្ញុំអង្វរសូមនូវជំនួយ ។*

اهْدِنَا الصِّرَاطَ الْمُسْتَقِيْمَ

*សូមព្រះអង្គមេត្តាដឹកនាំអស់ទូលព្រះបង្គំជាខ្ញុំឆ្ពោះទៅកាន់មាគ៌ាត្រង់ត្រូវ ។*

صِرَاطَ الَّذِيْنَ أَنْعَمْتَ عَلَيْهِمْ

*មាគ៌ារបស់បណ្តាអ្នកដែលព្រះអង្គបានព្រះរាជទានឲ្យនូវឧបការធម៌*

غَيْرِ الْمَغْضُوْبِ عَلَيْهِمْ وَلَا الضَّالِّيْنَ

*ពុំមែនបណ្តាអ្នកដែលទទួលរងនូវព្រះពិរោធទេ ហើយក៏ពុំមែនបណ្តាអ្នកវង្វេងខុសទេដែរ*

## មេរៀនទី ១៧

# ស៊ូរ៉ោះត៍ អាល់-ហ្វាទីហាស់ - ទន្លេញចាំរត់មាត់ - តាហ្វ់សៀរ

អល់ឡោះហ៍ﷻបានដាក់អាយ៉ាស់នេះមកឲ្យព្រះសាស្ដាﷺនៅឯម៉ាក់កាស់ និង នៅម៉ាឌីណាស់ដែរ ។ អត្ថន័យរបស់ព្រះមហាគម្ពីរគួរអានមូលនៅក្នុងស៊ូរ៉ោះត៍នេះ ពោលគឺ គោលដៅរបស់សាសនាអ៊ីស្លាម គឺ៖

១) សទ្ធានិងជំនឿលើព្រះអ្នកបង្កើតតែមួយ ព្រះម្ចាស់របស់ភពផែនដែន ចក្រវាល ។

២) ថ្ងៃជំនុំជម្រះ ពេលដែលមនុស្សរាល់គ្នានឹងត្រូវទទួលខុសត្រូវទង្វើរបស់ខ្លួន ។

៣) ស្ដាប់បង្គាប់អល់ឡោះហ៍ﷻទាំងស្រុង មិនពឹងផ្អែកលើអ្នកណាឡើយក្រៅពីព្រះអង្គﷻមួយគត់ ។

៤) តាមមាគ៌ាត្រង់ត្រូវ គឺមាគ៌ាដែលព្រះអង្គﷻបានបង្ហាញយើង ។

៥) ដកស្រង់យកពីប្រវត្តិសាស្រ្ត លទ្ធផលរបស់បុគ្គលដែលបានតាមមាគ៌ាត្រង់ត្រូវរបស់ព្រះអង្គﷻ គឺបុគ្គលដែលបានទទួលរង្វាន់ និងលទ្ធផលរបស់បុគ្គលដែលមិនបានតាមមាគ៌ាត្រង់ត្រូវទេ គឺបុគ្គលដែលត្រូវផ្ដន្ទាទោស ។

សារៈសំខានរបស់ស៊ូរ៉ោះត៍នេះ ស្ថិតនៅត្រង់ចំណុចដែលត្រូវដាក់ចុះមកនៅឯម៉ាក់កាស់និងនៅឯម៉ាឌីណាស់ នឹងស្ថិតនៅត្រង់ចំណុចដែលមុស្លីមគ្រប់គ្នាសូត្រស៊ូរ៉ោះត៍នេះដប់ដងក្នុងមួយថ្ងៃនៅក្នុងស្វ៏ឡាត់របស់ខ្លួន ។

បើពិចារណាអំពីអត្ថន័យរបស់ស៊ូរ៉ោះត៍នេះ ក្នុងពេលដែលអ្នកសូត្រវាក្នុងស្វ៏ឡាត់ វាកាន់តែធ្វើឲ្យការជឿជាក់របស់អ្នកចំពោះសិក្ខាបទអ៊ីស្លាមនោះមានកម្រិតខ្លាំងឡើង ។ វានឹងធ្វើឲ្យអ្នកលែងអួតខ្លួនឯងព្រោះអ្នកនឹងដឹងខ្លួនថាខ្លួនអ្នកមិនសំខាន់ទេប្រៀបធ្ធឹមនឹងអល់ឡោះហ៍ﷻ ។

ស៊ូរ៉ោះត៍នេះមានឈ្មោះច្រើន ។ ឈ្មោះល្បីជាងគេគឺ៖ អាល់-ហ្វាទីហ៊ាស់ មាន ន័យថាបុរេកថា (គឺបទដំបូង), ស៊ូរ៉ោះត៍ អ៊ុមុល-គីតាប មានន័យថាមាតាគម្ពីរ ឬ មេគម្ពីរ, ស៊ូរ៉ោះត៍ អាស់-សាប់អ៊ុល-ម៉ាស្សានី (اَلسَّبْعُ الْمَثَانِي) មានន័យថា ប្រាំពីរអាយ៉ាស់សូត្រសា ។

# លំហាត់ ១៥

ចូរគូរអ្វីដែលអ្នកបានសិក្សាពីស៊ូរ៉ោះត៍ អាល់-ហ្វាទីហ្ហាស់ ។

## ស៊ូរ៉ោះត៍ អាល់-ហ្វាទីហ្ហាស់